- គ្រប់គ្រងនិងចាត់ចែងថវិកាឧបត្ថម្ភធន ដែលផ្តល់ជូនគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ចាត់ចែង បញ្ជា និងជម្រះចំណូល និងធ្វើប្រតិបត្តិការចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងមូល ស្របតាមច្បាប់និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**ប្រការ៥.-**

ក្រោយពីទទួលបានប្រកាសស្តីពីការបែងចែកឥណទានរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រកាសប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្ទេរថវិកាឧបត្ថម្ភធន (ជំពូក៦៥) ដែលជាចំណែករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ចូលគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារជាតិជាចាំបាច់ ក្នុងរយៈពេលមួយត្រីមាសម្តង។ ចំណែកទឹកប្រាក់សម្រាប់ត្រីមាសនីមួយៗ អាចតិច ឬច្រើនជាងមួយភាគបួន នៃផែនការឆ្នាំ អាស្រ័យទៅតាមតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។ ថវិកាឧបត្ថម្ភធននេះ ត្រូវកត់ត្រាជាចំណូលថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងចំណាយថវិកាឧបត្ថម្ភធនរបស់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស។ អាណត្តិបើកប្រាក់ ត្រូវឆ្លងកាត់ការត្រួតពិនិត្យហិរញ្ញវត្ថុរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស។

**ប្រការ៦.-**

ប្រតិបត្តិការចំណូល ចំណាយទាំងអស់នៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវឆ្លងកាត់គណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ផ្នែកទី២**

**តួនាទីរបស់ប្រតិបត្តិ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ**

**ប្រការ៧.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជាអាណាប័កផ្ទេរសិទ្ធិនៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល មានសិទ្ធិពេញលេញក្នុងការចាត់ចែងប្រើប្រាស់ថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**ប្រការ៨.-**

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម÷

- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ យ៉ាងតិច ០៣ឆ្នាំ
- ធ្លាប់ឆ្លងកាត់វគ្គបណ្ដុះបណ្ដាលផ្នែកហិរញ្ញវត្ថុសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវតែងតាំងដោយក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស តាមសំណើរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល និងមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល។ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ជាសេនាធិការឱ្យនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ដោយត្រូវគោរពតាមវិធាននិងបទប្បញ្ញត្តិហិរញ្ញវត្ថុជាធរមាន។

**ប្រការ៩.-**

រដ្ឋលេខាធិការ/រតនាគារិក... 

រដ្ឋទេយ្យករចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវជ្រើសរើសនិងតែងតាំងពីក្នុងចំណោមមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម÷

- មានបទពិសោធន៍លើការងារគណនេយ្យ យ៉ាងតិច ១ឆ្នាំ
- ពុំធ្លាប់ទទួលការផ្ដន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ។

រដ្ឋទេយ្យករចំណូល អាចមានរដ្ឋទេយ្យករចំណូលរងជាជំនួយការតាមការចាំបាច់។

រដ្ឋទេយ្យករចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល មានភារកិច្ចនិងការទទួលខុសត្រូវ ដូចខាងក្រោម÷

- មានការទទួលខុសត្រូវផ្ទាល់ខ្លួនខាងផ្នែករដ្ឋបាល រដ្ឋប្បវេណី ព្រហ្មទណ្ឌ និងជាប្រាក់កាស ដែលខ្លួនបានទទួលកាន់កាប់
- ប្រមូលចំណូលជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ហើយបង់ចូលគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារជាតិ ជាចំណូលថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- កាន់កាប់បញ្ជីគណនេយ្យរដ្ឋទេយ្យចំណូល ថែរក្សាទុកដាក់លិខិតយុត្តិការដែលពាក់ព័ន្ធ។

រដ្ឋទេយ្យករចំណូល ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់នាយកគ្រឹះស្ថាន និងគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ប្រការ១០.-**

រដ្ឋទេយ្យករបុរេប្រទានរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវជ្រើសរើសនិងតែងតាំងពីក្នុងចំណោមមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម៖

- មានបទពិសោធន៍លើការងារគណនេយ្យយ៉ាងតិច ១ឆ្នាំ
- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ។

រដ្ឋទេយ្យករបុរេប្រទាន អាចមានរដ្ឋទេយ្យករបុរេប្រទានរងជាជំនួយការតាមការចាំបាច់។

រដ្ឋទេយ្យករបុរេប្រទានរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល មានភារកិច្ចនិងការទទួលខុសត្រូវ ដូចខាងក្រោម៖

- មានសិទ្ធិកាន់កាប់ប្រាក់កាសរដ្ឋទេយ្យបុរេប្រទានរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ទទួលខុសត្រូវផ្ទាល់ ខាងផ្នែករដ្ឋបាល រដ្ឋប្បវេណី ព្រហ្មទណ្ឌ និងប្រាក់កាស
- កាន់កាប់បញ្ជីគណនេយ្យនៃប្រតិបត្តិការរដ្ឋទេយ្យបុរេប្រទាន និងថែរក្សាទុកដាក់លិខិតយុត្តិការ។

រដ្ឋទេយ្យករបុរេប្រទាន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់នាយកគ្រឹះស្ថាន និងគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ប្រការ១១.-**

គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានលក្ខណសម្បត្តិស្របតាមការកំណត់ នៃបទប្បញ្ញត្តិជាធរមាន ហើយត្រូវជ្រើសរើសនិងតែងតាំងពីក្នុងចំណោមមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស ឬមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាលដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គណនេយ្យករ អាចមានជំនួយការតាមការចាំបាច់។

គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលមានភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រងការប្រមូលចំណូល
- ទូទាត់ចំណាយ
- កាន់កាប់បញ្ជីគណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល តាមគោលការណ៍ទ្វេភាគ
- ថែរក្សាទុកដាក់លិខិតយុត្តិការជាច្បាប់ដើម
- ចូលរួមរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ
- មានការទទួលខុសត្រូវផ្ទាល់ខ្លួន ខាងផ្នែករដ្ឋបាល រដ្ឋប្បវេណី និងព្រហ្មទណ្ឌ។

**ប្រការ១២.-**

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ជាមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ នៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ក្នុងករណីគ្រឹះស្ថានសាធារណៈរដ្ឋបាលមានទីតាំងនៅតាមបណ្តាខេត្ត មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវតែងតាំងពីក្នុងចំណោមមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃខេត្តដែលគ្រឹះស្ថានសាធារណៈរដ្ឋបាលនោះស្ថិតនៅ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានកម្រិតវប្បធម៌យ៉ាងតិចពីបរិញ្ញាបត្រឡើងទៅ, មានបទពិសោធន៍លើការងារត្រួតពិនិត្យហិរញ្ញវត្ថុ យ៉ាងតិច ០៣ឆ្នាំ និងពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ។

## ជំពូកទី៣

## នីតិវិធីអនុវត្តថវិកា

**ប្រការ១៣.-**

កិច្ចប្រតិបត្តិការចំណាយថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាលមាន ៤ ដំណាក់កាលសំខាន់ៗ÷

- ដំណាក់កាលធានាចំណាយ
- ដំណាក់កាលលទ្ធកម្មសាធារណៈ
- ដំណាក់កាលជម្រះបញ្ជី
- ដំណាក់កាលអាណត្តិកិច្ច និងទូទាត់។

## ផ្នែកទី១

## ការធានាចំណាយ

**ប្រការ១៤.-**

ប្រតិបត្តិការចំណាយថវិកា ត្រូវឆ្លងកាត់នីតិវិធីនៃការស្នើសុំធានាចំណាយ ដោយមានភ្ជាប់នូវលិខិតយុត្តិការពាក់ព័ន្ធគ្រប់គ្រាន់ និងត្រូវគោរពតាមឥណទានថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលបានវិភាជន៍ជូនពីដើមឆ្នាំ តាមចំណាត់ថ្នាក់សេដ្ឋកិច្ច និង/ឬតាមចំណាត់ថ្នាក់កម្មវិធី។

ធានាចំណាយព្រម÷ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ ត្រូវរៀបចំព្រមគ្នានូវសលាកបត្រកត់ត្រាចំណាយថវិកានិងត្រួតពិនិត្យហិរញ្ញវត្ថុ អាណត្តិបើកប្រាក់ ដីកាអមលិខិតយុត្តិការ ដីកាអមអាណត្តិបើកប្រាក់ និងលិខិតយុត្តិការទាំងអស់ដែលពាក់ព័ន្ធមុខសញ្ញា ឬកម្មវត្ថុចំណាយ ដើម្បីស្នើសុំការផ្តល់ទិដ្ឋាការលើអាណត្តិបើកប្រាក់ពីអភិបាលហិរញ្ញវត្ថុ ដូចមានក្នុងបរិបថជាឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

ធានាចំណាយបណ្តោះអាសន្ន÷ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជាអាណាប័កផ្ទេរសិទ្ធិ ត្រូវរៀបចំគម្រោងស្នើសុំចំណាយតាមមុខចំណាយនីមួយៗ ដើម្បីស្នើសុំការផ្តល់ទិដ្ឋាការធានាចំណាយពីអភិបាលហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវសលាកបត្រកត់ត្រាចំណាយថវិកា វិក្កយបត្របណ្តោះអាសន្ន និងគម្រោងចំណាយច្បាស់លាស់ ស្របតាមផែនការលទ្ធកម្ម និងឥណទានថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

ធានាចំណាយបណ្តោះអាសន្ន ត្រូវអនុវត្តតាមបរិបថដូចមានក្នុងឧបសម្ព័ន្ធទី២ និងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ប្រការ១៥.-**

ចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគោរពតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។ ចំណាយថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបែងចែក ដូចខាងក្រោម÷

ក. ចំណាយមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ រួមមាន÷



42 6

ក.១. ចំណាយព្រម÷

- ចំណាយតាមរជ្ជទេយ្យបុរេប្រទាន ត្រូវអនុវត្តទៅតាមប្រកាសលេខ ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ចំណាយព្រមផ្សេងៗទៀតជាអាទិ៍មាន ចំណាយលើប្រាក់បៀវត្ស ប្រាក់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ការប្រើប្រាស់ទឹក និងអគ្គិសនី ការប្រើប្រាស់ទូរសព្ទ ទូរសារ និងថ្លៃសេវាបញ្ញើប្រៃសណីយ៍ ចំណាយបង់ពន្ធ (ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្ត) និងចំណាយដែលមានគោលរបបកំណត់។

ក.២. ចំណាយតម្រូវឱ្យមានការស្នើសុំធានាចំណាយជាមុន មុនបោះផ្សាយអាណត្តិបើកប្រាក់មានជាអាទិ៍÷

- ប្រាក់លាភការ ប្រាក់បំណាច់ ប្រាក់ឧបត្ថម្ភផ្សេងៗ និងប្រាក់វិភាជន៍សង្គមសម្រាប់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ បុគ្គលិកជាប់កិច្ចសន្យា ដែលមិនទាន់មានគោលការណ៍កំណត់
- ចំណាយពាក់ព័ន្ធជាមួយសេវាកម្មផ្សេងៗ(ជំពូក៦១) ចំណាយសម្រាប់អត្ថប្រយោជន៍សង្គម (ជំពូក៦២) ដែលមិនតម្រូវឱ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ប៉ុន្តែមិនទាន់មានគោលការណ៍កំណត់ច្បាស់លាស់។
- ចំណាយបុរេប្រទានដែលមិនទាក់ទងកិច្ចលទ្ធកម្មសាធារណៈ។

ខ. ចំណាយតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ជាប្រភេទចំណាយដែលតម្រូវឱ្យមានការស្នើសុំធានាចំណាយ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ មុនបោះផ្សាយអាណត្តិទូទាត់។

ចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ រួមមាន÷

- ការទិញ
- ការជួសជុល
- ការសាងសង់
- ការជួលសេវា
- ចំណាយថវិកាបុរេប្រទាន ដែលមុខសញ្ញាចំណាយតម្រូវឱ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

**ប្រការ១៦._**

អនុញ្ញាតផ្តល់បុរេប្រទានសម្រាប់ការងារ ដែលមានលក្ខណៈចាំបាច់និងបន្ទាន់។

អនុញ្ញាតផ្តល់បុរេប្រទានសម្រាប់បំពេញសមតុល្យគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល នៅរតនាគារជាតិ សម្រាប់បម្រើឱ្យការងារចាំបាច់និងបន្ទាន់។

ការចំណាយថវិកាបុរេប្រទាន ត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**ផ្នែកទី២**

**លទ្ធកម្មសាធារណៈ**

**ប្រការ១៧._**

កិច្ចលទ្ធកម្មរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវប្រតិបត្តិដោយអង្គភាពប្រតិបត្តិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលគ្រប់គ្រងនិងដឹកនាំអនុវត្តដោយគណៈកម្មាធិការលទ្ធកម្មមួយ ដែលមាននាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ជាប្រធាន និងមានអង្គភាពលទ្ធកម្មមួយ ជាលេខាធិការដ្ឋាន។ ប្រធានអង្គភាពលទ្ធកម្ម ជាលេខាធិការរបស់គណៈកម្មាធិការលទ្ធកម្ម។

**ប្រការ១៨.-**

គណៈកម្មាធិការលទ្ធកម្ម ត្រូវបានបង្កើតដោយសេចក្តីសម្រេចរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយមានការអនុម័តយល់ព្រមពីក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងនិងដឹកនាំការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ឱ្យសមស្របតាមគោលការណ៍ វិធាន វិធីសាស្ត្រដែលបានកំណត់ដោយច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ១៩.-**

អង្គភាពលទ្ធកម្ម ត្រូវបានបង្កើតដោយសេចក្តីសម្រេចរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយមានការអនុម័តយល់ព្រមពីក្រុមប្រឹក្សាភិបាល។ អង្គភាពលទ្ធកម្ម មានរចនាសម្ព័ន្ធច្បាស់លាស់ និងមានមន្ត្រីមានសមត្ថភាពជំនាញផ្នែកលទ្ធកម្មសាធារណៈគ្រប់គ្រាន់ ព្រមទាំងមានសិទ្ធិអំណាចសមស្របដើម្បីទទួលខុសត្រូវអនុវត្តរាល់កិច្ចលទ្ធកម្មសាធារណៈ។

ប្រធានអង្គភាពលទ្ធកម្មត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម÷

- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឬហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬហិរញ្ញវត្ថុ យ៉ាងតិច ៣ឆ្នាំ
- ធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកលទ្ធកម្មសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២០.-**

កិច្ចលទ្ធកម្មសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវប្រតិបត្តិតាមគោលការណ៍ វិធីសាស្ត្រ នីតិវិធីលទ្ធកម្មដូចគ្នាទៅនឹងនៅគ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម និងអនុលោមតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៣
## កិច្ចជម្រះបញ្ជី

**ប្រការ២១.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវទទួលខុសត្រូវលើកិច្ចជម្រះបញ្ជី។

កិច្ចជម្រះបញ្ជីអាចធ្វើទៅបានបន្ទាប់ពីការបញ្ជាទិញ កិច្ចសន្យាលទ្ធកម្មទំនិញ សំណង់ ឬសេវានានា ត្រូវបានបំពេញរួចរាល់។

កិច្ចជម្រះបញ្ជី ធ្វើឡើងដើម្បីផ្ទៀងផ្ទាត់ភាពពិតប្រាកដនៃការធានាចំណាយ និងត្រៀមទឹកប្រាក់ទុកសម្រាប់ទូទាត់ឱ្យម្ចាស់បំណុល។

## ផ្នែកទី៤
## អាណត្តិកិច្ច និងការទូទាត់

**ប្រការ២២.-**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ ដោយឆ្លងការត្រួតពិនិត្យហិរញ្ញវត្ថុ ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។

អាណត្តិបើកប្រាក់ ដែលគ្មានទិដ្ឋាការពីអភិបាលហិរញ្ញវត្ថុ ឬមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ គឺពុំអាចប្រើប្រាស់បានសម្រាប់ការទូទាត់ ឬដកប្រាក់ពីគណនីប្រាក់បញ្ញើនៅរតនាគារជាតិបានឡើយ។

រតនាគារជាតិ ត្រូវធ្វើការដកប្រាក់ចេញពីគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជូនគ្រឹះស្ថានសាធារណៈរដ្ឋបាល តាមរូបភាពបង្វែរ ឬមូលប្បទានបត្រ ក្រោយពីទទួលបានសំណើសុំដកប្រាក់ ដោយភ្ជាប់ជាមួយអាណត្តិបើកប្រាក់ជាច្បាប់ថតចម្លង។

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ត្រូវរៀបចំឯកសារនិងលិខិតយុត្តិការពាក់ព័ន្ធ អនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន រួចដាក់ជូននាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីបោះផ្សាយអាណត្តិបើកប្រាក់ និងសុំទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ក្រោយពីបានការឯកភាពពីគណនេយ្យករ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំលិខិតទៅរតនាគារជាតិ ដើម្បីសុំដកសាច់ប្រាក់ ឬផ្ទេរប្រាក់ពីគណនីប្រាក់បញ្ញើរបស់ខ្លួន តាមចំនួនទឹកប្រាក់នៅលើអាណត្តិបើកប្រាក់ ដូចមានក្នុងបរិបថជាឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

## ផ្នែកទី៥

## ការចលនាឥណទាន

**ប្រការ២៣.-**

ការផ្ទេរឥណទាន ឬនិយ័តភាពឥណទាន អាចអនុវត្តបាននៅក្នុងត្រីមាសទី២ នៃឆ្នាំថវិកា សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេសអនុវត្តថវិកាកម្មវិធី និងនៅក្នុងត្រីមាសទី៣ នៃឆ្នាំថវិកា សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេសអនុវត្តថវិកាមិនមែនកម្មវិធី។ នីតិវិធីផ្ទេរឥណទាន ត្រូវអនុលោមតាមមាត្រា១៣ នៃអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។

## ផ្នែកទី៦

## កិច្ចបញ្ជិកាគណនេយ្យ

**ប្រការ២៤.-**

គោលការណ៍នៃកិច្ចបញ្ជិកាគណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំស្របតាមវិធានទូទៅ និងប្លង់គណនេយ្យសាធារណៈ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ១៣៩៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្ដីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរជ្ជទេយ្យបុរេប្រទាន និងគណនេយ្យរជ្ជទេយ្យចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

## ជំពូកទី៤

## របាយការណ៍

**ប្រការ២៥.-**

គ្រឹះស្ថានសាធារណៈរដ្ឋបាល មានកាតព្វកិច្ចរៀបចំរបាយការណ៍បីប្រភេទគឺ÷

១. របាយការណ៍អនុវត្តថវិកា

២. របាយការណ៍សមិទ្ធកម្ម

៣. របាយការណ៍ហិរញ្ញវត្ថុ។

**របាយការណ៍អនុវត្តថវិកា** ជារបាយការណ៍ដែលវិភាគអំពីស្ថានភាពអនុវត្តថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និង/ឬតាមចំណាត់ថ្នាក់កម្មវិធីប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ដោយអនុលោមទៅតាមគំរូនៃប្រភេទរបាយការណ៍របស់គ្រឹះស្ថាន

សាធារណៈរដ្ឋបាល។ របាយការណ៍អនុវត្តថវិកា ត្រូវបង្ហាញអំពីលទ្ធផលដែលសម្រេចបានក្នុងឆ្នាំសារពើពន្ធធៀបជាមួយនឹងលទ្ធផលអនុវត្តនៅឆ្នាំមុនៗ។

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំរបាយការណ៍អនុវត្តថវិកា រួចផ្ញើមកអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ក្រសួងស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ ទៅតាមកាលវិភាគ ដូចខាងក្រោម÷

- យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៣ នៃខែនៅដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាសនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ទៅតាមជំពូកចំណាយ
- យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៣ បន្ទាប់ពីបញ្ចប់នៃឆមាសនីមួយៗ សម្រាប់របាយការណ៍ចំណាយប្រចាំឆមាសនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ទៅតាមជំពូកចំណាយ
- យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៣ នៃខែកក្កដា របាយការណ៍ចំណូល-ចំណាយ សម្រាប់ការត្រួតពិនិត្យពាក់កណ្តាលឆ្នាំ តាមចំណាត់ថ្នាក់សេដ្ឋកិច្ច
- យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៣ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ចំណូល-ចំណាយប្រចាំឆ្នាំ តាមចំណាត់ថ្នាក់សេដ្ឋកិច្ច
- យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៣ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ចំណាយប្រចាំឆ្នាំ នៃការអនុវត្ត កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ទៅតាមជំពូកចំណាយ។

**របាយការណ៍សមិទ្ធកម្ម** គឺជារបាយការណ៍ដែលឆ្លុះបញ្ចាំងអំពីលទ្ធផលនិងវឌ្ឍនភាព នៃការអនុវត្តការងារតាមកម្មវិធី អនុកម្មវិធី ឬចង្កោមសកម្មភាព ដើម្បីរួមចំណែកសម្រេចគោលបំណង និងគោលនយោបាយរបស់ក្រសួង ស្ថាប័ន។ គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវតាមដានការអនុវត្តថវិការបស់ខ្លួនជាប្រចាំ និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពលើសូចនាករលទ្ធផលក្នុងឆ្នាំជាចាំបាច់ និងសូចនាករលទ្ធផលចុងក្រោយ ដោយអនុលោមទៅតាមទម្រង់តារាងគំរូរួម និងតាមទម្រង់នៃប្រភេទរបាយការណ៍ ដែលត្រូវដាក់ឱ្យអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

របាយការណ៍សមិទ្ធកម្មទាំងអស់ ត្រូវធ្វើឡើងតាមកាលវិភាគ ដូចខាងក្រោម ÷

- របាយការណ៍សមិទ្ធកម្មប្រចាំឆមាស ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៣ បន្ទាប់ពីបញ្ចប់នៃឆមាសនីមួយៗ
- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៣ ខែមករា នៃឆ្នាំបន្ទាប់។

របាយការណ៍អនុវត្តថវិកា និងរបាយការណ៍សមិទ្ធកម្ម ត្រូវផ្ញើជូនក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ។

**របាយការណ៍ហិរញ្ញវត្ថុ** គឺជារបាយការណ៍ដែលឆ្លុះបញ្ចាំងអំពីស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល នាពេលកំណត់មួយច្បាស់លាស់។ របាយការណ៍ហិរញ្ញវត្ថុ រួមមាន តារាងតុល្យការ របាយការណ៍លទ្ធផល និងរបាយការណ៍ផ្សេងទៀត ស្របតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ របាយការណ៍ទាំងនេះ ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត រួចផ្ញើជូនក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងផ្តល់ការយល់ព្រម។

**ប្រការ២៦.–**

អតិរេករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល។ អតិរេកនេះ ត្រូវមានការបញ្ជាក់ទទួលស្គាល់ពីក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ។

អតិរេកនេះ អាចត្រូវបានចាត់ចែង សម្រាប់ការវិនិយោគជាប្រយោជន៍ដល់ការអភិវឌ្ឍគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬជាកម្មវត្ថុនៃការបង់ចូលថវិកាជាតិ។ ការចាត់ចែងអតិរេកនេះ ត្រូវមានការយល់ព្រមពីក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំនិងដាក់ឱ្យអនុវត្តប្រកាសស្តីពីការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់អតិរេករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ២៧._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៨._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ២៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១

នៃប្រកាសលេខ១៧៦ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល



ឧបសម្ព័ន្ធទី២

នៃប្រកាសលេខ៣៧១ចុះថ្ងៃទី១៣ខែកុម្ភៈ ឆ្នាំ ២០១៧ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល



ឧបសម្ព័ន្ធទី៣

នៃប្រកាសលេខ១៧១ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល



ឧបសម្ព័ន្ធទី៤

នៃប្រកាសលេខ១៧១ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៧២ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

14

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៥០០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៥៨៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ៨៣៨ សហវ.ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់វគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា នៃក្រសួង ស្ថាប័នថវិកាកម្មវិធី
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងការពិនិត្យនិងសម្រេចផ្តល់បុរេប្រទាន ទិដ្ឋាការធានាចំណាយ និងអាណត្តិបើកប្រាក់របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដូចខាងក្រោម÷

ក. គ្រប់មុខសញ្ញាចំណាយដែលមានទឹកប្រាក់អតិបរមាត្រឹមចំនួន ៣០០ លានរៀល

ខ. មុខសញ្ញាចំណាយ ដែលមានរបបកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអាទិ៍ បេសកកម្ម សិក្ខាសាលា ប្រាក់ឧបត្ថម្ភ ប្រាក់កម្រៃដោយពុំកំណត់ចំនួនទឹកប្រាក់។

គ. មុខសញ្ញាចំណាយ ជាអាទិ៍ ទឹក អគ្គិសនី ទូរសព្ទ បង់ពន្ធដោយពុំកំណត់ចំនួនទឹកប្រាក់។

ឃ. បុរេប្រទានក្នុងកម្រិតអតិបរមាត្រឹមចំនួន ១៥០ លានរៀល សម្រាប់មុខសញ្ញាចំណាយដែលមានលក្ខណៈចាំបាច់និងបន្ទាន់ ក្នុងករណីមានសមតុល្យគ្រប់គ្រាន់ក្នុងគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារជាតិ។

ង. គ្រប់អាណត្តិបើកប្រាក់របស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដោយពុំកំណត់ចំនួនទឹកប្រាក់។

ករណីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុពិនិត្យឃើញថា សំណើចំណាយថវិកាទាំងឡាយណាមានវេទយិតភាព ត្រូវស្នើសុំការសម្រេចពីថ្នាក់ដឹកនាំតាមឋានានុក្រម។

**ប្រការ២.–**

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវស្នើសុំការសម្រេចពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះការស្នើសុំបុរេប្រទាន និងធានាចំណាយរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដូចខាងក្រោម÷

ក. មុខសញ្ញាចំណាយដែលមិនមានរបបកំណត់ និងមានទឹកប្រាក់លើសពី ៣០០ លានរៀល

ខ. បុរេប្រទានដែលមានចំនួនទឹកប្រាក់លើសពី ១៥០ លានរៀល។

**ប្រការ៣.–**

មិនអនុញ្ញាតឱ្យធ្វើការបំបែកគម្រោងចំណាយ ដើម្បីតម្រូវទៅតាមកម្រិតទឹកប្រាក់ដែលបានប្រគល់សិទ្ធិ។

**ប្រការ៤.–**

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល មានកាតព្វកិច្ចនិងភារកិច្ច ដូចខាងក្រោម÷

- សិក្សាស្វែងយល់អំពីគោលបំណងគោលនយោបាយ និងទិសដៅកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល
- សិក្សាស្វែងយល់ និងរៀនសូត្រជាប្រចាំអំពីមូលដ្ឋានគ្រឹះសំខាន់ៗ នៃលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សិក្សាស្វែងយល់អំពីគោលបំណងគោលនយោបាយក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងកម្មវិធីសកម្មភាពការងាររបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ធានាឱ្យមានប្រសិទ្ធភាពនៃការអនុវត្តថវិកា ដោយគោរពឱ្យបានហ្មត់ចត់នូវវិន័យថវិកា គោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- ផ្សព្វផ្សាយ ផ្តល់យោបល់ ណែនាំអំពីលិខិតបទដ្ឋានគតិយុត្ត នីតិវិធីចំណូល ចំណាយ ដល់អាណាប័កផ្ទេរសិទ្ធិ និងមន្ត្រីជំនាញពាក់ព័ន្ធ ក្នុងគោលបំណងលើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពជំនាញគ្រប់គ្រងថវិកានៅគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ត្រួតពិនិត្យចំណូលទាំងអស់របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ត្រួតពិនិត្យជាមុនអំពីភាពត្រឹមត្រូវនៃការស្នើសុំធានាចំណាយ ផ្ទៀងផ្ទាត់ឥណទាន ដែលបានការអនុម័តឥណទានទំនេរ សមតុល្យគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល



4

- ផ្តល់ទិដ្ឋាការលើលិខិតធានាចំណាយ និងលើអាណត្តិបើកប្រាក់តាមមុខសញ្ញាចំណាយ ដូចមានក្នុងប្រការ១ ក្នុងរយៈពេលយ៉ាងយូរ ៣ ថ្ងៃ នៃថ្ងៃធ្វើការ ជូនគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយអនុលោម តាមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន
- ផ្តល់យោបល់ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេចលើសំណើសុំធានាចំណាយ សម្រាប់មុខសញ្ញាចំណាយ ដែលមិនស្ថិតក្រោមសិទ្ធិអំណាចដែលបានប្រគល់ជូន
- ត្រួតពិនិត្យឯកសារ និងលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ធ្វើការផ្ទៀងផ្ទាត់តួលេខអនុវត្តថវិកាជាប្រចាំជាមួយមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ធ្វើរបាយការណ៍ប្រចាំខែអំពីការសម្រេចទាំងឡាយរបស់ខ្លួន ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រម ឱ្យបានទៀងទាត់
- ចូលរួមរៀបចំថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ចូលរួមកិច្ចប្រជុំផ្សេងៗដែលពាក់ព័ន្ធនឹងការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ប្រការ៥.-**

ក្នុងការបំពេញមុខងារតាមការប្រគល់សិទ្ធិខាងលើ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គនាយកហិរញ្ញវត្ថុ សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានទីតាំងនៅរាជធានីភ្នំពេញ និងមានសិទ្ធិប្រើប្រាស់ត្រារបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានទីតាំងនៅតាមបណ្តាខេត្ត។

**ប្រការ៦.-**

មន្ត្រី ១ (មួយ) រូប មិនអាចត្រូវបានតែងតាំងជាមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល លើសពីមួយកន្លែងបានឡើយ។

**ប្រការ៧.-**

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវរាល់កិច្ចការរបស់ខ្លួន។

**ប្រការ៨.-**

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ដោយមិនគិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណី ចំពោះសកម្មភាពដែលបានប្រព្រឹត្ត ឬសមគំនិតក្នុងការប្រព្រឹត្ត។ អនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ទណ្ឌកម្មរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល រួមមានជាអាទិ៍÷

- ការស្តីបន្ទោស
- ការផ្លាស់កន្លែងធ្វើការដោយបង្ខំតាមវិធានការខាងវិន័យ
- ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យនៅទំនេរគ្មានបៀវត្ស

- ការបន្ថយឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យចូលនិវត្តន៍មុនកំណត់
- ការបញ្ឈប់ពីការងារដោយបង្ខំ ឬការបណ្តេញចេញពីមុខតំណែងជាមន្ត្រីរាជការ។

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ[illegible] ឆ្នាំ២០១៧*

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
  "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ការគ្រប់គ្រងឆ្នាំ ២០១៧

## សលាកប័ត្រកត់ត្រាចំណាយថវិកា
## និង ត្រួតពិនិត្យហិរញ្ញវត្ថុ

ឈ្មោះគ្រឹះស្ថានៈ..................................

**បន្ទុកចំណាយថវិកា**

លេខកូដៈ

កម្មវិធី/អនុកម្មវិធីៈ..................................

ជំពូក :..................................................

គណនី :..................................................

អនុគណនី :..................................................

**ស្ថានភាពឥណទានថវិកា**

ឥណទានអនុម័ត :...................................... ៛

ចលនាឥណទាន :...................................... ៛

ឥណទានថ្មី :...................................... ៛

ធានាចំណាយពីមុន :...................................... ៛

ឥណទានទំនេរ :...................................... ៛

ស្នើសុំលើកនេះ :...................................... ៛

ឥណទានសល់ទំនេរ :...................................... ៛

**កម្មវត្ថុនៃការធានាចំណាយ:**

**ផ្នែកទទួលបន្ទុកចំណាយ:**

**សក្ខីប័ត្រ:**

**កន្លែងសម្រាប់អាណាប័កផ្ទេរសិទ្ធិ:**

ហត្ថលេខា និងត្រា

កាលបរិច្ឆេទ:

ចម្លើយតបទៅនឹងកំណត់សំគាល់របស់អភិបាលហិរញ្ញវត្ថុ:

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

កាលបរិច្ឆេទ:

**កន្លែងសម្រាប់អភិបាលហិរញ្ញវត្ថុ:**

ទិដ្ឋាការ ឬកំណត់សម្គាល់

របស់អភិបាលហិរញ្ញវត្ថុ:

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

កាលបរិច្ឆេទ:

ទិដ្ឋាការអភិបាលហិរញ្ញវត្ថុ

កាលបរិច្ឆេទ:

ព្រះរាជាណាចក្រកម្ពុជា

ការគ្រប់គ្រងឆ្នាំ ២០១៧

# អាណត្តិបើកប្រាក់គ្រឹះស្ថានសាធារណៈរដ្ឋបាល

ឈ្មោះគ្រឹះស្ថានៈ ..............................................

លេខកូដៈ ..........................

លេខអាណត្តិៈ

| ជំពូក-គណនី-អនុគណនី | ចំនួនទឹកប្រាក់ | កម្មវត្ថុចំណាយ-ឈ្មោះសក្ខីប័ត្រ | ឈ្មោះកម្មវិធី/អនុកម្មវិធី |
| --- | --- | --- | --- |
| | | | |
| សរុបរួមៈ | | ឈ្មោះអង្គភាពចំណាយៈ | |

ឈ្មោះ និងអាសយដ្ឋានអត្ថគាហកៈ

របៀបបង់ទូទាត់ៈ ☐ បង្វែរ ☐ មូលប្បទានប័ត្រ

លេខគណនីៈ

អាសយដ្ឋានធនាគារ ឬធនាគារៈ

អាណត្តិនេះកំណត់ត្រឹមទឹកប្រាក់ចំនួនៈ..............................................................................................................

ហត្ថលេខា និងត្រា របស់អាណាប័កផ្ទេរសិទ្ធិ

កាលបរិច្ឆេទៈ

**និយ្យាការអតិបាលហិរញ្ញវត្ថុ**

លេខសលាកប័ត្រៈ

ហត្ថលេខា និងត្រា

កាលបរិច្ឆេទៈ

**កន្លែងសម្រាប់គណនេយ្យករ**

ចំនួនទឹកប្រាក់នៃអាណត្តិៈ ........................................

ការជំទាស់ និងការដកហូតទុកៈ ........................................

ចំនួនទឹកប្រាក់ពិតត្រូវបើកៈ ........................................

បានឃើញ និងអនុញ្ញាតឱ្យបើកផ្តល់

ហត្ថលេខា និងត្រា

កាលបរិច្ឆេទៈ

---

# អាណត្តិបើកប្រាក់គ្រឹះស្ថានសាធារណៈរដ្ឋបាល

លេខអាណត្តិៈ

ឈ្មោះគ្រឹះស្ថានៈ .................................

លេខកូដៈ ..........................

កាលបរិច្ឆេទៈ

| ជំពូក-គណនី-អនុគណនី | ចំនួនទឹកប្រាក់ | កម្មវត្ថុចំណាយ-ឈ្មោះសក្ខីប័ត្រ |
| --- | --- | --- |
| | | |
| សរុបរួមៈ | | ឈ្មោះអង្គភាពចំណាយៈ |

អាណត្តិនេះកំណត់ត្រឹមទឹកប្រាក់ចំនួនៈ..............................................................................................................

ឈ្មោះ និងអាសយដ្ឋានអត្ថគាហកៈ

**កន្លែងសម្រាប់គណនេយ្យករ**

ចំនួនទឹកប្រាក់នៃអាណត្តិៈ ........................................

ការជំទាស់ និងការដកហូតទុកៈ ........................................

ចំនួនទឹកប្រាក់ពិតត្រូវបើកៈ ........................................

របៀបបង់ទូទាត់ៈ ☐ បង្វែរ ☐ មូលប្បទានប័ត្រ

លេខគណនីៈ

អាសយដ្ឋានធនាគារ ឬធនាគារៈ

បានឃើញ និងអនុញ្ញាតឱ្យបើកផ្តល់

ហត្ថលេខា និងត្រា

កាលបរិច្ឆេទៈ

V

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៧៦ សហវ.ក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរង្វាន់លើកទឹកចិត្តប្រចាំឆ្នាំសម្រាប់ឆ្នាំ២០១៧

## ការបង្កើតរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០១៧
## របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ-បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា ៤៥ មាត្រា ៤៦ និងមាត្រា ៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ប្រកាសលេខ ២៥៤ MIH / 2016 ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត ការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## សម្រេច

**ប្រការ១**-

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ" , ជំពូក៦១ "សេវាកម្ម" នៅក្រសួងឧស្សាហកម្ម និងសិប្បកម្មសម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ នៃប្រកាស៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និង ប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

**ប្រការ២**-

ចំនួនទឹកប្រាក់១ជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣**-

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានវិទ្យាស្ថាន និងប្រធាននាយកដ្ឋានរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល៖</u>**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
អគ្គនាយកដ្ឋានកិច្ចការទូទៅ
នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

## តារាងឧបសម្ព័ន្ធឥណទានផ្ទេរជាបុរេប្រទានថវិកាតាមកម្មវិធីឆ្នាំ២០១៧

ឯកតាគិតរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧ | ឥណទាន ដែលជ្រើសរើស | ឥណទាន ផ្ទេរជាបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន១ជុំបង្វិលផ្ទេរជាបុរេប្រទាន | ភាគរយ% |
|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4=2-3 | 5=3/4ជុំ | 6=3/2 |
| | | | **សរុបរួម** | **15,901,800,000** | **9,820,600,000** | **4,264,600,000** | **5,556,000,000** | **1,066,150,000** | **43.43%** |
| 60 | | | **ការទិញ** | **6,814,600,000** | **4,207,600,000** | **1,962,600,000** | **2,245,000,000** | **490,650,000** | **46.64%** |
| | 6001 | | សម្ភារផ្គត់ផ្គង់ថែទាំ | **749,600,000** | **249,600,000** | **249,600,000** | - | **62,400,000** | **100.00%** |
| | | 60011 | សម្ភារផ្គត់ផ្គង់ សម្អាត និងអនាម័យ | 100,000,000 | 100,000,000 | 100,000,000 | - | 25,000,000 | 100.00% |
| | | 60012 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអាគារ ប្រាសាទ និងសំណង់ផ្សេងៗ | 9,600,000 | 9,600,000 | 9,600,000 | - | 2,400,000 | 100.00% |
| | | 60014 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារឧបករណ៍ | 140,000,000 | 140,000,000 | 140,000,000 | - | 35,000,000 | 100.00% |
| | | 60015 | ប្រេងឥន្ធនៈ និងប្រេងរំអិល | 500,000,000 | - | - | - | - | 0.00% |
| | 6002 | | សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល | **1,400,000,000** | **1,400,000,000** | **650,000,000** | **750,000,000** | **162,500,000** | **46.43%** |
| | | 60021 | សម្ភារការិយាល័យ និងការបោះពុម្ព | 1,350,500,000 | 1,350,500,000 | 600,500,000 | 750,000,000 | 150,125,000 | 44.47% |
| | | 60022 | សៀវភៅមើល និងឯកសារ | 30,000,000 | 30,000,000 | 30,000,000 | - | 7,500,000 | 100.00% |
| | | 60028 | សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ | 19,500,000 | 19,500,000 | 19,500,000 | - | 4,875,000 | 100.00% |
| | 6004 | | សម្លៀកបំពាក់និងការតុបតែង | **536,000,000** | **6,000,000** | **6,000,000** | - | **1,500,000** | **100.00%** |
| | | 60041 | ឯកសណ្ឋាន | 530,000,000 | - | - | - | - | 0.00% |
| | | 60042 | សម្លៀកបំពាក់ការពារសុវត្ថិភាព | 6,000,000 | 6,000,000 | 6,000,000 | - | 1,500,000 | 100.00% |
| | 6005 | | សម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារ | **2,582,000,000** | **2,042,000,000** | **847,000,000** | **1,195,000,000** | **211,750,000** | **41.48%** |
| | | 60051 | សម្ភារ និងបរិក្ខារបច្ចេកទេស | 1,302,000,000 | 1,302,000,000 | 407,000,000 | 895,000,000 | 101,750,000 | 31.26% |
| | | 60052 | សង្ហារឹម | 700,000,000 | 700,000,000 | 400,000,000 | 300,000,000 | 100,000,000 | 57.14% |
| | | 60053 | សម្ភារប្រើប្រាស់ | 40,000,000 | 40,000,000 | 40,000,000 | - | 10,000,000 | 100.00% |
| | | 60054 | សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន | 540,000,000 | - | - | - | - | 0.00% |
| | 6006 | | ថាមពលនិងទឹក | **1,037,000,000** | - | - | - | - | **0.00%** |
| | | 60061 | អគ្គិសនី | 1,000,000,000 | - | - | - | - | 0.00% |
| | | 60062 | ទឹក | 37,000,000 | - | - | - | - | 0.00% |
| | 6098 | | សម្ភារផ្គត់ផ្គង់ផ្សេងៗ | **510,000,000** | **510,000,000** | **210,000,000** | **300,000,000** | **52,500,000** | **41.18%** |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 61 | | | **សេវាកម្ម** | **9,087,200,000** | **5,613,000,000** | **2,302,000,000** | **3,311,000,000** | **575,500,000** | **41.01%** |
| | 6101 | | កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស | **6,000,000** | - | - | - | - | **0.00%** |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | **101,000,000** | - | - | - | - | **0.00%** |
| | 6103 | | ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម) | - | - | - | - | - | **0.00%** |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុងនិងក្រៅប្រទេស | **100,000,000** | - | - | - | - | **0.00%** |
| | 6105 | | ការថែទាំ និងជួសជុល | **1,333,000,000** | **1,333,000,000** | **933,000,000** | **400,000,000** | **233,250,000** | **69.99%** |
| | | 61051 | ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងដែនទេសាទ | 13,000,000 | 13,000,000 | 13,000,000 | - | 3,250,000 | 100.00% |
| | | 61052 | ការថែទាំ ជួសជុលអាគារផ្សេងៗ និងប្រាសាទ | 800,000,000 | 800,000,000 | 400,000,000 | 400,000,000 | 100,000,000 | 50.00% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 180,000,000 | 180,000,000 | 180,000,000 | - | 45,000,000 | 100.00% |
| | | 61056 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | 172,000,000 | 172,000,000 | 172,000,000 | - | 43,000,000 | 100.00% |
| | | 61057 | ការថែទាំ និងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស | 148,000,000 | 148,000,000 | 148,000,000 | - | 37,000,000 | 100.00% |
| | | 61058 | ការថែទាំ និងជួសជុលផ្សេងៗ | 20,000,000 | 20,000,000 | 20,000,000 | - | 5,000,000 | 100.00% |
| | 6107 | | សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវានិងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | **65,000,000** | **65,000,000** | **65,000,000** | - | **16,250,000** | **100.00%** |
| | | 61071 | សោហ៊ុយសិក្សាពិសោធន៍ | 65,000,000 | 65,000,000 | 65,000,000 | - | 16,250,000 | 100.00% |
| | | 61073 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | - | - | - | - | - | 0.00% |
| | 6108 | | សោហ៊ុយដឹកជញ្ជូន | **180,000,000** | - | - | - | - | **0.00%** |
| | | 61081 | សម្ភារៈ និងទំនិញ | 90,000,000 | - | - | - | - | 0.00% |
| | | 61088 | សោហ៊ុយដឹកជញ្ជូនផ្សេងៗ | 90,000,000 | - | - | - | - | 0.00% |
| | 6110 | | ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ | **3,305,000,000** | **2,475,000,000** | **866,000,000** | **1,609,000,000** | **216,500,000** | **34.99%** |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 60,000,000 | 60,000,000 | 60,000,000 | - | 15,000,000 | 100.00% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 60,000,000 | 60,000,000 | 60,000,000 | - | 15,000,000 | 100.00% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 2,275,000,000 | 2,275,000,000 | 680,000,000 | 1,595,000,000 | 170,000,000 | 29.89% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 20,000,000 | 20,000,000 | 6,000,000 | 14,000,000 | 1,500,000 | 30.00% |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស | 30,000,000 | - | - | - | - | 0.00% |
| | | 61106 | ចំណាយសម្រាប់ការតាំងពិព័រណ៍នៅក្នុងនិងក្រៅប្រទេស | 800,000,000 | - | - | - | - | 0.00% |
| | | 61107 | ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 45,000,000 | 45,000,000 | 45,000,000 | - | 11,250,000 | 100.00% |
| | | 61108 | សោហ៊ុយទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយផ្សេងៗ | 15,000,000 | 15,000,000 | 15,000,000 | - | 3,750,000 | 100.00% |
| | 6111 | | ចំណាយលើការជាវសារព័ត៌មាននិងឯកសារ | **40,000,000** | **40,000,000** | **40,000,000** | - | **10,000,000** | **100.00%** |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.00% |
| | | 61112 | ចំណាយលើការជាវទស្សនាវដ្តី | 10,000,000 | 10,000,000 | 10,000,000 | - | 2,500,000 | 100.00% |
| | | 61113 | ចំណាយលើការជាវសៀវភៅរាជកិច្ច | - | - | - | - | - | 0.00% |
| | | 61118 | ចំណាយលើការជាវសារព័ត៌មាន និងឯកសារផ្សេងៗ | 20,000,000 | 20,000,000 | 20,000,000 | - | 5,000,000 | 100.00% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | **1,700,000,000** | **1,700,000,000** | **398,000,000** | **1,302,000,000** | **99,500,000** | **23.41%** |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 364,900,000 | 364,900,000 | 90,000,000 | 274,900,000 | 22,500,000 | 24.66% |
| | | 61122 | សោហ៊ុយបេសកកម្ម | 358,600,000 | 358,600,000 | 108,000,000 | 250,600,000 | 27,000,000 | 30.12% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 61123 | សោហ៊ុយស្នាក់នៅ | 976,500,000 | 976,500,000 | 200,000,000 | 776,500,000 | 50,000,000 | 20.48% |
| | | 61128 | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេសផ្សេងៗ | - | - | - | - | - | 0.00% |
| | 6113 | | **ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស** | **2,200,000,000** | - | - | - | - | **0.00%** |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 660,200,000 | - | - | - | - | 0.00% |
| | | 61132 | សោហ៊ុយបេសកកម្ម | 289,500,000 | - | - | - | - | 0.00% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 1,250,300,000 | - | - | - | - | 0.00% |
| | | 61138 | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេសផ្សេងៗ | - | - | - | - | - | 0.00% |
| | 6114 | | **សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍** | **57,200,000** | - | - | - | - | **0.00%** |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 3,800,000 | - | - | - | - | 0.00% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 53,400,000 | - | - | - | - | 0.00% |

**បានឃើញនិងពិនិត្យត្រឹមត្រូវ**
រាជធានីភ្នំពេញ, ថ្ងៃទី... ខែ... ឆ្នាំ២០១៧
អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
បណ្ឌិត វង្ស ប៊ុនឥន្ទ្រាវុធ

**បានឃើញនិងពិនិត្យត្រឹមត្រូវ**
រាជធានីភ្នំពេញ, ថ្ងៃទី... ខែ... ឆ្នាំ២០១៧
អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
**គុក-មឹម**

**បានឃើញនិងពិនិត្យត្រឹមត្រូវ**
រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧
អគ្គនាយក
អគ្គនាយកដ្ឋានកិច្ចការទូទៅ
**ស៊ីន-សុធា**

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧
រដ្ឋលេខាធិការប្រធាន
វ៉ែន លន់

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ, ថ្ងៃទី... ខែ... ឆ្នាំ២០១៧
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**បានឃើញ និងឯកភាព**
រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**ចម-ប្រសិទ្ធ**

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្តីការគណៈរដ្ឋមន្ត្រី